ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែធ្នូ ឆ្នាំ២០១៥

*នៅក្នុងខែធ្នូ ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

*-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០២លើក*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងសម័យប្រជុំ វិសាមញ្ញព្រឹទ្ធសភាចំនួន០៣លើក*

*-អញ្ជើញចូលរួមជូន និងទទួលព្រះរាជដំណើរ* ***ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្តេចយាងបំពេញព្រះរាជទស្សនកិច្ច នៅសាធារណរដ្ឋបារាំង និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ*

*-ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាព នៅសាធារណរដ្ឋសង្គមនិយមវៀតណាម*

*-អនុញ្ញាតឲ្យឯកឧត្តម* Mian Rabbani *ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន ព្រមទាំងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ*

*-អនុញ្ញាតឲ្យឯកឧត្តម* TRAN VAN HANG *ប្រធានគណៈកម្មាធិការកិច្ចការបរទេសរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម*

*-ទទួលសារតាំងពីឯកឧត្តម* George EDGAR *ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃស្ថានប្រតិភូសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

-ទទួលសារតាំងពីឯកឧត្តម William A.Heidt ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាអធិបតីក្នុងពិធីបើកមហាសន្និបាតលើកទី៨ នៃសភាតំបន់អាស៊ីAPA របស់សភាតំបន់អាស៊ី ក្រោមប្រធានបទ" ការជំរុញ សន្តិភាព ការផ្សះផ្សា និងការសន្ទនា ក្នុងតំបន់អាស៊ី"

-អញ្ជើញចូលរួមក្នុងពិធីដង្ហែសពមហាឧបាសិកា **ឡោ លាងហ៊ន់** ដែលត្រូវជាម្តាយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងពត៌មាន ដែលបានទទួលមរណភាពកាលពីថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងជន្មាយុ៨៨ឆ្នាំ ដោយរោគាពាធ

-អញ្ជើញចុះសំណេះសំណាល រំលែកទុក្ខជាមួយក្រុមគ្រួសារសពឯកឧត្តម **ជ្រាង សុផាន់** អភិបាលរងរាជធានីភ្នំពេញ ដែលបានទទួលមរណភាពកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងជន្មាយុ៥៦ឆ្នាំ ដោយរោគាពាធ

-អញ្ជើញចុះសំណេះសំណាល រំលែកទុក្ខជាមួយក្រុមគ្រួសារសពឯកឧត្តម **អ៊ឹង ជុនហួរ** ទីប្រឹក្សាក្រសួងសាធារណការ និងដឹកជញ្ជូន ដែលបានទទួលមរណភាពកាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ក្នុងជន្មាយុ ៦៨ឆ្នាំ ដោយរោគាពាធ

-អញ្ជើញចុះទៅសាលាសង្កាត់ព្រែកប្រា ក្នុងខណ្ឌច្បារអំពៅ និងជួបសំណេះសំណាល សួរសុខទុក្ខ ស្តាប់សំណូមពរ និងស្វែងយល់អំពីស្ថានភាព ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ និងការងាររបស់ក្រុមប្រឹក្សាសង្កាត់ មន្ត្រី ថ្នាក់ដឹកនាំភូមិ ជាពិសេសការងារបំរើសេវាសាធារណៈ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៤៥ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា ប្ដាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៥លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៣លើក

-អនុញ្ញាតឲ្យឯកឧត្តម **ផាន់ យុនហឺ** ប្រធានគណៈកម្មាធិការកិច្ចការបរទេស

នៃសភា ប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្តែងការគួរសម

-អញ្ជើញចូលរួមជូន និងទទួលដំណើរ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភាអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២១ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាប្បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៥លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញចូលរួមជូនដំណើរ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភាអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថា បើកសិក្ខាសាលា ស្តីពី" ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការប្រជាធិបតេយ្យ"

-អញ្ជើញចូលរួមក្នុងពិធីបើកមហាសន្និបាត (APA) លើកទី៨ របស់សភាតំបន់អាស៊ីក្រោមប្រធានបទ " ការជំរុញ សន្តិភាព ការផ្សះផ្សា និងការសន្ទនា ក្នុងតំបន់អាស៊ី"

-អញ្ជើញជួបសំណេះសំណាល និងនាំសមាគមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំង ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ ក្នុងឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញចូលរួមក្នុងពិធីជប់លៀងជូនគណៈប្រតិភូចិន ដឹកនាំដោយ ឯកឧត្តម Shen Chuyao អគ្គលេខាធិការរងនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រជាជនចិន

-អនុញ្ញាតឲ្យឯកឧត្តម MiKi WANATABEសមាជិកព្រឹទ្ធសភាជប៉ុន និងជាប្រធានក្រុមមិត្តភាពសមាជិកសភាជប៉ុន-មេគង្គ ចូលជួបសម្តែងការគួរសម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៨៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៧២ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៥លើកដើម្បី ៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០៥ ទៅគណៈកម្មការជំនាញ

និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា៖

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីស្ថិតិ

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ សម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការការពារពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស

៥.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន

៦.ពិនិត្យ និងសម្រេចសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

៧.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំវិសាមញ្ញចំនួន០៣លើកដើម្បី៖**

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍

៣.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីស្ថិតិ

៤.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការការពារពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស

៥.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ច

ព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន

៦.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ។

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែធ្នូនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាង ០៥ ច្បាប់

-ប្រជុំពិនិត្យ ពិភាក្សាអំពីការរៀបចំសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន០៥ករណី ទទួលលិខិតឆ្លើយតបពីសាលាខេត្តកំពង់ឆ្នាំងចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន០១ករណី

-រៀបចំវេទិកាថ្នាក់ខេត្តស្តីពី "ការបង្កើនសមត្ថភាព និងការអភិវឌ្ឍមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់" នៅខេត្តកំពង់ធំ

-រៀបចំសិក្ខាសាលាស្តីពី " ការរួមចំណែករបស់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងដំណើរការសភាប្រជាធិបតេយ្យ " និងសិក្ខាសាលាស្តីពី " ទំនាក់ទំនងកម្ពុជា-ចិន តាមរយៈយុទ្ធសាស្ត្រខ្សែក្រវាត់១ ផ្លូវ១ " សហការរៀបចំដោយវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិតសភាកម្ពុជា ជាមួយស្ថានទូតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ប្រជុំជាមួយសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ក្រុមមិត្តភាពកម្ពុជា-ជប៉ុន ប្រជុំត្រៀមលក្ខណៈទទួលប្រធានព្រឹទ្ធសភាជប៉ុន មកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងក្រុមសមាជិកាព្រឹទ្ធសភាប្រជុំពិគ្រោះយោបល់អំពីឯកសារទស្សនទាន ស្តីពីការផ្សព្វផ្សាយព័ត៌មានសភាទៅកាន់មូលដ្ឋាន

-ប្រជុំពិនិត្យ និងសម្រេចលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៃមហាសន្និបាតលើកទី៨ នៃសភាប្រជាជាតិអាស៊ី (APA)

-ចូលរួមវេទិកាថ្នាក់ជាតិស្តីពី " ស្ត្រីជាថ្នាក់ដឹកនាំ ក្នុងវិស័យសាធារណៈ និងនយោបាយ "

-ចូលរួមកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី" បច្ចុប្បន្នភាពនៃច្បាប់សិទ្ធិទទួលបានព័ត៌មាន "

-ចូលរួមសិក្ខាសាលាស្តីពី " ឱកាសសហគ្រិនកម្ពុជា "

-អនុញ្ញាតឲ្យឯកឧត្តម **NAVEEN SRIVASTVA** ឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធទៅនឹងវិស័យវិនិយោគ

-ជួបពិភាក្សាការងារជាមួយលោក **គឹមយាត ដារ៉ារិទ្ធ** នាយកប្រតិបត្តិវិទ្យាស្ថានសភាកម្ពុជាស្តីពី តួនាទី និងភារកិច្ចរបស់វិទ្យាស្ថានសភាកម្ពុជា

-ជួបជាមួយសាស្ត្រាចារ្យបណ្ឌិត John Pieris សមាជិកព្រឹទ្ធសភា និងជាប្រធានទីភ្នាក់ងារអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន នៃសភាតំបន់នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ស្តីអំពីដំណើរការតាក់តែងច្បាប់ និងតួនាទី ភារកិច្ច សមត្ថកិច្ចរបស់ស្ថាប័នព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១០០លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤០លើក។

**៤.៣. មុខងារត្រួតពិនិត្យ**

-ជួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងទេសចរណ៍ ដើម្បីស្វែងយល់អំពីការ

អនុវត្តច្បាប់ វឌ្ឍនភាពសំខាន់ និងបញ្ហាប្រឈមនានា ដែលពាក់ព័ន្ធទៅនឹងវិស័យទេសចរណ៍ នៅទីស្តីការក្រសួងទេសចរណ៍

-ជួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីស្វែងយល់ពីទិសដៅការងារសំរាប់វិស័យទូរគមនាគមន៍ នៅកម្ពុជា នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**៤.៤. មុខងារព័ត៌មាន**

-អញ្ជើញចុះបេសកកម្មដើម្បីស្វែងយល់អំពី របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ឃុំ-សង្កាត់ នៅមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក-ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ក្រុង, ការអនុវត្តច្បាប់ និងរបៀបដោះស្រាយដីធ្លីរបស់គណៈកម្មការសុរិយោដី, ការអនុវត្តក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងមន្ត្រីនគរបាលយុត្តិធម៌ ( កងរាជអាវុធហត្ថ នគរបាល មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលមាននីតិសម្បទា ពិសេសសំរាប់ពិនិត្យ និងទប់ស្កាត់បទល្មើសព្រហ្មទណ្ឌមួយចំនួនរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បរិស្ថាន ពាណិជ្ជកម្ម កិច្ចការនារី ហិរញ្ញវត្ថុ ឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរសាធារណការ និងដឹកជញ្ជូន) នៅខេត្តកំពង់ធំ និងខេត្តសៀមរាប ។

-អញ្ជើញចុះបេសកកម្មដើម្បីស្វែងយល់អំពី ការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើបញ្ហាសុខភាពសាធារណៈ នៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

-អញ្ជើញចុះបេសកកម្មដើម្បីស្វែងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងការដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ នៅខេត្តរតនគិរី ស្ទឹងត្រែង និងខេត្តព្រះវិហារ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ មាន សំអាន,ឯកឧត្តម **ឡាវ ម៉េងឃីន** បានអញ្ជើញអមដំណើរគណៈប្រតិភូរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមកិច្ចប្រជុំស្តីពីគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃ លើកទី២ នៅទីក្រុងបាងកក ប្រទេសថៃ

-ឯកឧត្តម **គង់ គាំ**, ឯកឧត្តម **យ៉ង់ សែម**, ឯកឧត្តម **ចេប គីមអ៊ាង**, លោកជំទាវ **ឡាយ បូនី** និងឯកឧត្តម **អ៊ុក គង់** បានអញ្ជើញទៅបំពេញបេសកកម្ម ដើម្បីស្វែងយល់អំពីសិទ្ធិជនជាតិដើមភាគតិច នៅប្រទេសនូវែលសេឡង់

-លោកជំទាវ **មាន សំអាន** និងឯកឧត្តម **ម៉ាន់ ឈឿន** បានអញ្ជើញអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **គង់ សារាជ**, លោកជំទាវ **ពុំ ស៊ីចាន់**, ឯកឧត្តម **ម៉ែង- ស៊ីផាន់** និងឯកឧត្តម **ហុង ទូហាយ** បានអញ្ជើញចូលរួមកិច្ចប្រជុំសភានិយាយភាសាបារាំង (APF) ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក លើកទី៧ នៅក្រុងហូជីមិញ សាធារណរដ្ឋវៀតណាម

-ឯកឧត្តម **ឈិត គីមយាត លោកជំទាវ មាន សំអាន** បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍអន្តរជាតិរវាងប្រទេសចិន និងប្រទេសអ៊ីរ៉ង់ នៅទីក្រុង Haikou នៃសាធារណរដ្ឋប្រជាមានិតចិន ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ